-គាត់បញ្ជាអោយយកទៅសំរាកនៅមន្ទីរពេទ្យធំ

ភ្លាមនោះគេបានបញ្ចូលអ្នករបួសចូលក្នុងរថយន្តយ៉ាងរហ័ស ហើយរថយន្តនោះក៏បានបើកចេញយ៉ាងលឿន ពីវិទ្យាលោកសំអាត ។

បូផលស្រាប់តែចាប់អារម្មណ៍រឿងមួយ នាយស្រែក :

-សែម ! ឆាប់ឡើងទៅលើភ្លាម ! យើងចាញ់បោកក្អែបខ្មៅហើយ ! ម៉េចហ្នឹងលោក ? " សែបសួរ "

-គ្មានម៉េចទេ ! ម៉ោងដប់ពីរជាងហើយ នៅមិនឃើញវាមកទៀតបានន័យថា វាមករួចហើយតាមរយៈអ្នករបួសអម្បាញ់មិញ! វីវរហើយ យើងប្រាកដជាចាញ់បោកវា !

-ម៉េច !

ទាំងពីរនាក់រត់ឡើងទៅកាន់បន្ទប់គ្លីនិច !

-តុក ៗ ! ៗ ! .....

គ្មានសំលេងឆ្លើយ បូផលច្រានទ្វារចូល នាយឃើញលោកដុកទ័រសំអាតរមូរសដួចជ្រូកក្នុងដុចក្រោមគ្រែព្យាបាល :

-លោកដុកទ័រ ! យ៉ាងម៉េចហ្នឹង ! សែបឆាប់ជួយស្រាយអោយលោកដុកទ័រផង !



សែមប្រញាប់ស្រាយចំណង :

-យីអស្ចារ្យណាស់ ! គ្នាគគោក បណ្តោយអោយចាញ់បោកក្អែបខ្មៅទៅកើត ..... លោកអធិការប្រញាប់ចាត់គ្នាយើងអោយតាមវាភ្លាម .....

បូផលគ្រវីក្បាល :

-ឥតអំពើទេសែម ! វាគេចខ្លួនបាត់ទៅហើយ ......

ក្រោយពីស្រាយចំណង និងដកឆ្នុកមាត់រួចហើយ លោកដុកទ័រ គ្រវីក្បាលថ្ងូរដូចព្រាប :

-អស្ចារ្យណាស់លោកអើយ អាចោរនេះឆើតមែន វាលេងមួយបានបោកទាំងឯង បោកទាំងប៉ូលីសទៀត គួរអោយសរសើរវាណាស់ !

បូផលក្រឡេកភ្នែកលើតុ នាយឃើញរូបក្អែបខ្មៅធ្វើពីជ័របួស្តិចយ៉ាងស្រស់ ក៏ស្ទុះទៅចាប់យកមកមើលដោយក្តៅក្រយាយៈ

-ក្អែបខ្មៅ ! សកម្មភាពរបស់ឯងអាចឹកំចាំង និងប៉ុនប្រសព្វណាស់ ! តែមិនអីទេ បើចាប់ឯងមិនបានទេ ! យើងក៏មិនព្រមធ្វើតិញសំងាត់ដែរ ហ៊ឹស !

បូផលដើរមកជិតលោកដុកទ័រដែលអង្គុយធ្វើមុខជូរ :

-វាមានធ្វើអីលោកទេ ?

-គោតតែលោកសួរទៅកើត .... លោកមិនឃើញវាចងខ្ញុំក្រញោន១ ទេឬ ?

-ក្រៅពីនេះទៀតណា?

-វាយកប្រាក់រលីងពីទូដែកទៅហើយ លោកមិនឃើញទូចំហរទេឬ?

មែនទ្វារទូដែកត្រូវចំហរ ។ បូផលអេះក្បាលយ៉ាងញាប់:

-សូមលោកស្ងប់ចិត្តសិនចុះ ! ខ្ញុំនឹងតាមរកចោរក្លែបខ្មៅអោយទាល់តែឃើញ ......

-ហ៊ី ! " លោកសំអាតដកដង្ហើមធំ " វាបានអោយដំណឹងមុនថា វានឹងមកទីនេះយើងទប់ទល់មិនបានទៅហើយទំរាំនឹងទៅរកចាប់វាទៀត ដូចជាមិនសង្ឃឹមទេលោក .....

-លោកកុំអាលអស់សង្ឃឹម វាអាចសំរេចបានដោយសារយើងមិនបានជាចាប់ភ្លឹកថាវានឹងដើរតួជាអ្នកជំងឺយ៉ាងនេះសោះ ! ណ្ហើយ! អស់ការហើយខ្ញុំសូមលាលោកសិនហើយណា !

លោកសំអាតមិនបានជូនដំណើរភ្ញៀវទេ គាត់កំពុងតែពិបាកចិត្ត ។



## ឃាតកម្មទីមួយ

ព្រឹត្តិការណ៍ដែលកើតឡើងដោយសារសកម្មភាពរបស់ចោរក្លែបខ្មៅបានលេចឮខ្ចរខ្ចាយពេញទីក្រុងយ៉ាងរហ័ស បណ្តាលអោយអ្នកមាន១ ក្នុងក្រុងមានការភ័យព្រួយ និងបារម្ភក្រៃលែងពិសេសចំពោះអ្នកដែលបានជួបនឹងក្លែបខ្មៅរួចហើយ ។

ទន្ទឹមនឹងគ្នានេះ ខាងគិញសំងាត់ក៏កំពុងវិលក្បូងណាស់ដែរ ព្រោះក្លែបខ្មៅមិនត្រឹមតែជួបពួកអ្នកមានយ៉ាងអាថ៌កំបាំងប៉ុណ្ណោះទេ ថែមទាំងធ្វើសកម្មភាពក្រោមភ្នែកអធិការបូផលដោយបោកបញ្ឆោតអធិការដើង ធើតនេះអោយដូលអុកគូថមួយបានយ៉ាងដំណំ។

លោកអធិការបូផលចាប់ផ្ដើមមានការស្មុគ្រស្មាញ ព្រោះតាំងពីដើមមកពុំទាន់មានជនទុច្ចរិតណាមើលងាយសមត្ថភាពគាត់ដូចលើកនេះទេ ។ ហេតុនេះដើម្បីរក្សាកេរ្តិ៍ឈ្មោះរបស់គាត់ៗ ត្រូវតែប្រើអស់លទ្ធភាព ដើម្បីស្រាវជ្រាវរកប្រភពរបស់ជនក្អែបខ្មៅ ។

ភ្នាក់ងារសំងាត់បានបង្កប់ស្ទើរតែគ្រប់កន្លែងតាមភោជនីយដ្ឋាន រោងកុន ល្ខោន ផ្ទះបនពេស្យា កន្លែងសាធារណៈដូចជាតាមមាត់សមុទ្រ កែប បូកគោ ទឹកឈូ តែស្រមោលរបស់ក្អែបខ្មៅនៅតែភ្ញីបភ្លែតដដែល ។

ក្រៅពីការប្លន់យកប្រាក់ មិនទាន់ឃើញក្អែបខ្មៅសំលាប់មនុស្សនៅឡើយទេ ។

លោកបូផលបើឡានផ្វែលទីក្រុងបន្តិច រួចក៏បង្ហួសទៅផ្ទះរបស់រតនានៅម្តុំផ្សារស៊ីឡឹប ។

-ទីន១ ..... " នាយស៊ីប្លេឡានជាសញ្ញា "

ស្រីចាស់ម្នាក់ចេញមកបើកទ្វារ :

-អុំស្រី ! រតនានៅទេ ?

-ចាស ! នាងនៅខាងក្នុង !

បូផល បត់ឡានចូលហើយចតក្រោមម្លប់ដើមទឹកដោះ រួច



បើកទ្វារឡានចេញទៅក្រៅ ។

-រតនា ! ៗ ! " អុំចាស់ស្រែកហៅ "

-ចាស !

-ក្មួយ បូផល មករកកូន

-ចាស ! អោយគាត់ឡើងមក !

-បូផលឡើងតាមកាំជណ្តើរ ។ រតនា ស្ទុះចេញមក

-បង ! ថ្ងៃនេះផ្ទះអូនមានកិត្តិយសធំណាស់ដែលលោកអធិការមកលេង .....

-ស្អប់ រតនា ! បានសំដីណាស់អូនឯង ! តើកន្លងមកបងមិនដែលមកលេងទេឬ ?

រតនា សើច :

-បងមកដែរ ! តែមិនមែនពីព្រឹកដូច្នេះទេ !

-មកពីបងតប់ប្រមល់ពេកអូន !

-តប់ប្រមល់រឿងអីទៅបង ?

-រឿង *ក្អែបខ្មៅ* នោះណា ! បងដូចជាចង់ចាញ់វាហើយអូន

-យ៉ាងម៉េច ? បងអស់សមត្ថភាពនឹងចាប់វាហើយឬ ? តាមយោបល់អូន *ក្អែបខ្មៅ* ឥតបង្កអីនាំអោយប៉ះពាល់ដល់សង្គមទេ !

-តែវាធ្វើអោយចលាចលពេញទាំងទីក្រុងណា

-នេះគឺបង្អើលអ្នកមានទេតើ ! បងឯងមិនឃើញក្នុងប៉ុន្មានថ្ងៃនេះពួកអ្នកមាន១ នាំគ្នាប្រមូលប្រាក់យកទៅដាក់បង់អស់ហើយទេឬ ?

-ឃើញហើយ ! តែ *ក្អែបខ្មៅ* មើលងាយប៉ូលីសសំងាត់ណាអូន!

រតនា ចាប់ដៃសង្សារ :

-មកបង ! អង្គុយលេងសិន ! សឹមនិយាយគ្នាទៀត

បូផលអង្គុយពីមុខតុទទួលភ្ញៀវ នាយលើកកែវភេសជ្ជៈដែលសង្សារចាក់អោយក្រេបបន្តិច ។

-បងអ្នា ! និយាយអីចឹង ! បងដែលជួបមុខក្អែបខ្មៅទេ ?

-ទេ ! មិនដែលសោះ ! បើបានជួបមុខក្អែបខ្មៅជាការប្រសើរហើយ ទោះត្រូវចាញ់វាក៏បងអស់ចិត្តដែរ .....

រតនា សើចឃឹក១ :

-ចុះកាលដែលបងប្រាប់អូនថា *ក្អែបខ្មៅ* ក្លែងធ្វើជាអ្នករបួសជួបបងដើម្បីទៅអោយលោកសំអាតព្យាបាលនោះយ៉ាងម៉េចទៅ ! ហ្នឹងមិនបងឯងចាញ់វាឬ ?

បូផល រឹងថ្គាមបន្តិច :



-មើលទៅអូនឯងដូចជាចង់ផ្ចាញ់បងដើម្បីលើកមុខអាក្អែបខ្មៅណាស់ ...... អូនឯងចូលចិត្តវាឬ ?

-ទេ១ ... " រតនា ប្រកែកញាប់មាត់ " កុំមានប្រសាសន៍ដូច្នេះបងសំលាញ់ អូនគ្មានគោលបំណងដូច្នោះទេ តែអូនឃើញសមត្ថភាពរបស់ក្អែបខ្មៅខ្ពស់ជាងបងណា ! ពិសេសគឺកលល្បិច !

-អូនកុំអាលសរសើរវា នេះមកពីបងមិនបានចាប់ភ្លឹក ! តែតាំងពីប្លន់លោកសំអាតហើយ *ក្អែបខ្មៅ* មិនទាន់ចេញសំដែងសកម្មភាពទៀតទេ ......

-បងសន្និដ្ឋានថាវាចុះចាញ់បងឬ ?

-បងមិនសន្និដ្ឋានថាវាចុះចាញ់បងទេ តែបងហ៊ានថាវាប្រហែលជាមិនសូវក្លាហានដូចមុនដែរ :

-អូនមិនទាន់ហ៊ានសន្និដ្ឋានទេ ..... ថ្ងៃនេះបងទំនេរឬ ?

-និយាយរឿងទំនេរគ្មានទេ ..... អូនមានការអីឬ ?

រតនា ញញឹមខ្ចឹប បង្ហាញសំរស់របស់នាងល្អត្រកាល

-គ្មានការអីទេ ! តែបើបងទំនេរយើងនាំគ្នាដើរលេង ! បងចូលចិត្តទេ ?

-បំពេញបំណងអូនជានិច្ច !

-យើងគិតទៅណា ?

-ស្រេចតែអូនទេ !

-កែប !

-បាន !

-អីចឹងអូនស្លៀកពាក់ណា ! បងចាំមួយភ្លែក !

រតនាស្លៀកពាក់យ៉ាងរហ័ស ហើយរៀបចំនំចំណីហើយស្រេច

-ម៉ោងប៉ុន្មានយើងមកវិញ?

-ម៉ោងបួនរសៀលហើយ ! កុំស្ងួវយប់ពេក ! ពេលបងមិននៅក្រុង ចោរក្អែបខ្មៅអាចចេញធ្វើសកម្មភាពរបស់វាណា !

-បានហើយបង ! កុំស្ងួវគិតច្រើនពេក ! ចោរក្អែបខ្មៅវាមិនប្លន់អ្នកក្រអត់បាយស៊ីទេ ។ ពួកអ្នកមានអស់នោះ ទោះជាក្អែបខ្មៅប្លន់ប៉ុណ្ណោះក៏វាមិនអត់បាយដែរ បងឯងជឿអូនចុះ ...

-បានហើយៗ ... យើងចេញដំណើរ ! បងរកស្ដាប់អូនមិនបានសោះ !

-រតនា យួរកន្ត្រកចុះពីលើផ្ទះ ដោយងាកទៅផ្ដាំនឹងអ៊ុំចាស់ថា:



-អ៊ុំ ! ថ្ងៃនេះខ្ញុំទៅលេងកែបណា !

-ចាស់ ! នាងទៅឆាប់មកវិញទេ ?

-ចាស់ ! ម៉ោងបួនល្ងាច ខ្ញុំមកវិញហើយ !

រថយន្តផ្ទាល់ខ្លួនរបស់បូផល លូនយ៉ាងលឿនតាមបណ្ដោយផ្លូវជាតិលេខបួនឆ្ពោះទៅកាន់គោលដៅ រតនាកើយលើស្មារបុរសស្នេហ៍ជាទីស្រលាញ់ :

-ម៉េចទៅបង រឿងការស្រលាញ់គ្នារបស់យើង ! ម៉ាក់មានប្រសាសន៍ថាម៉េចទេ ?

បូផល ងាកមើលមុខស្រីស្នេហ៍បន្តិច :

-ហ៊ឺ ... នាយដកដង្ហើមវែងដោយឥតចេញវាចារដូចម្ដេចឡើយ ធ្វើអោយរតនា ដាក់ទឹកមុខបន្តិច :

-យ៉ាងម៉េច ? គាត់ជំទាស់មែនទេ ?

បូផលងក់ក្បាលមិនចេញស្ដី ។ រតនាបន្ត

-មកពីម៉ាក់បងឃើញអូនក្រមែនទេ ?

បូផលនៅស្ងៀម រតនា បន្តដោយទឹកមុខស្ងប់ស្ងាត់ :

-បើគាត់ជំទាស់អីចឹងហើយ ! បងនៅរាប់អានអូនដល់ណាទៀត ? គួរតែបងបែរទៅបំពេញតាមគោលបំណងម្ដាយទើបត្រឹម

ត្រូវ !

បូផលថើបសក់សង្សារថ្នមៗ តែភ្នែកនៅតែសំលឹងទៅកាន់ផងផ្លូវវែងសណ្តូកត្រង់ទៅមុខ :

-កុំនិយាយអីចឹងអូន ! បងមិនអាចអត់អូនបានទេ ! ជាតិនេះបូផលរឹងដូចដែកចំពោះមុខការប្រយុទ្ធតែបូផលចុះចាញ់ចំពោះក្ដីស្នេហ៍បរិសុទ្ធរវាងអូននិងបងណារតនា ! បើម៉ាក់នៅតែមិនព្រមសំរួលដល់រឿងស្នេហារវាងយើងទាំងពីរទេនោះ បងសុខចិត្តនៅលីវដូច្នេះរហូត គឺបងមិនបោះបង់អូនចោលទេ ហើយក៏មិនអាចរៀបការនឹងនារីណាផ្សេងទៀតបានដែរ ?

រតនាពេញចិត្តនឹងសំដីរបស់សង្សារណាស់ នាងងាកទៅម្ខាងហើយសំរ៉ក់ទឹកភ្នែកតក់ៗ ចុះមក :

-អូនរំភើបចំពោះទឹកចិត្ត និង សំដីបងណាស់ ធ្វើដូច្នេះបានន័យថាអូនបង្ខិតបង្ខំបងអោយលះបង់អនាគតដោយសារតែស្រីមួយរូបណា ....

-មិនពិតដូច្នោះទេអូន ! សេចក្ដីស្នេហាដែលមានភាពស្មោះបរិសុទ្ធល្អ ត្រូវតែមានភាពដាច់ណាត់ដូច្នេះហើយ ! បងជឿថាម៉ាក់ត្រូវតែយល់ដល់ចិត្តបង ហើយនឹងអាណិតអូនជាមិនខាន ពេល



នោះគាត់ ប្រាកដជាអនុញ្ញាតអោយយើងរៀបការ... ហើយយើងអាចសាងសុភមង្គលមួយជាមួយគ្នាបានណា !

រតនាអង្អែលទ្រូងប្រុសស្នេហ៍ដោយទឹកចិត្តស្នេហាសែនជ្រាលជ្រៅ :

-បងសំលាញ់ ! បងមានចិត្តប្រពៃគួរកោតគោរពណាស់ ! ជាតិនេះអូនក៏មានគំនិតដូចបងដែរ អូនមិនអាចរស់នៅជាមួយប្រុសដទៃបានទេ !

រថយន្តចេះតែវិលកង់ទៅមុខឥតអាក់ ឯការសន្ទនារវាងគូសង្សារក៏រអិលទៅមុខដែរ មិនយូរប៉ុន្មានគេក៏បានមកដល់ក្រុងកែបតាមបំណង ។

សំរស់ក្រុងកែប ប្រៀបបាននឹងស្ថានសួគ៌ក្នុងបទចំរៀងមែនផ្ទៃទឹកសមុទ្រមានពណ៌ខៀវស្រងាត់ជាប់ជើងមេឃ

-ដោយមានសត្វរំពេហើរផ្ទៀលឆ្វាត់ពីលើផ្ទៃទឹក ដ៏មានរលកអង្កាញ់ៗដូចពស់លូន ។

ក្រោមរស្មីនៃព្រះសូរិយា យើងមើលឃើញពន្លឺព្រិមៗ លើផ្ទៃទឹករលកប្រៀបបាននឹងស្រកានាគ ។

តាមមាត់ច្រាំងដែលមានថ្មរកេញរកុញ ដើមដូងយោល

យោគចុះទៀងហាក់ស្វាគមន៍ចំពោះភ្ញៀវដែលមកដល់ទីនេះ ។

ក្រោមម្លប់ដូងគូសង្សារកំពុងកៀកគើយគ្នាលើផ្នូកខ្សាច់យ៉ាងអណ្ដែកអណ្ដូង ។

បូផលចតរថយន្ត នាយដឹកដៃសង្សារដើរស្រូបយកខ្យល់អាកាសលើមាត់ច្រាំង ស្ដាប់សូរលកដែលបោកលើថ្មាំងថ្ម បង្កើតជាតន្ត្រី ធម្មជាតិយ៉ាងពិរោះលន្លង់លន្លោចរិតតែញាំងអោយថានសូគ៏ក្នុងក្ដីស្រម៉ៃនេះ មានភាពរស់រវើកមួយកំរិតទៀត ។

-រតនា ! យើងរកផ្ទះសំណាក់សិន ! អូនចាំបងមួយភ្លែតណា ! បងទៅប្រាប់អោយគេទុកបន្ទប់អោយយើងមួយ !

-ចាស់ ! ឆាប់មកវិញណាបង .....

-ហ្នឹងហើយ ! បូផលបោះជំហានចាកចេញពីសង្សារ ដែលតាមសំលឹងដំណើរនាយឥតដាច់រហូតបាំងបាត់នឹងជ្រុងនៃអាគារមួយ ។

រតនា អង្គុយឱបក្បាលជង្គង់សំលឹងទៅកាន់ផ្ទៃទឹកសមុទ្រដែលកំពុងដេញពន្លឺថ្ងៃព្រិចៗ នាងកំពុងស្រម៉ៃដល់អនាគតមួយវែងឆ្ងាយ ។

ភ្លាមនោះ នាងភ្ញាក់ព្រើតនឹងសំរិបជើងមនុស្សពីរនាក់ដែល



បោះជំហានមករកនាង នាងចាប់អារម្មណ៍ភ្លាម ព្រោះដំណើររបស់វាមិនមានភាពធម្មតា ។

មកដល់ពីមុខនាង អាមួយពោលថា :

-យី ! អូនស្រី ! មកចាំបងយូរហើយឬ ? មកអូនយើងទៅខាងណោះ !

-អាភ្លើ ! គ្មានអ្នកណាមកចាំអ្វែងទេ !

ពាក្យជេររបស់រតនា ធ្វើអោយពួកវាសើចហាស់ៗ ព្រមគ្នាអាមួយលាន់មាត់ :

-អៃយ៉ា ! ជេរពិរោះផងតើ ! មកអូនជេរបងថែមបន្តិចទៀត! ហាស់ ! ៗ ! ៗ !

ថារួចវានាំគ្នាស្ទុះមកប្រុងចាប់រតនា តែភ្លាមនោះយើងស្មានថារតនាមុខជាត្រូវពួកវាចាប់យ៉ាងប្រាកដ តែខកសោះយើងឃើញរតនាក្រឡះខ្លួនយ៉ាងរហ័ស ហើយទាត់ពួកវាជាច់ៗ រហ័សស្ទើរមើលមិនទាន់ ។

ត្រូវម្នាក់មួយជើង អាអ្នកលេងទាំងពីរធ្វើមុខស្អុយប៉ែរ :

-អៃយ៉ា ! ខ្លាញីទេតើ ! អញស្មាញតែឈ្លូសញី ! យើងប្រយ័ត្នបន្តិចវ៉ើយ ! ហក ... ម្ដងទៀត ...

តែម្តងនេះក៏ដូចតែលើកមុនដែរ គ្រាន់តែគេហក់ភ្លែតមកភ្លាម រតនាក្រាបភ្លឹបហើយក្តាប់ដីខ្សាច់បាចផ្ទាច់ .....

-អូយ ! មេចោរចង្រៃ ! វាបាចដីខ្សាច់ ! អូយ !

ទន្ទឹមនឹងការប្រកាច់របស់វា រតនាលោតភ្លែតហើយទាត់ផាច់ ! រួចនាងក្រឡាស់ខ្លួនកាប់អាមួយផាំងបណ្តាលអោយវាខ្ទាតទៅម្ខាង ឆ្លៀតឱកាសដ៏ខ្លីនោះ រតនាលោតទៅអុកមួយកួយដៃចំកញ្ចឹងកអាមួយទៀត បណ្តាលអោយវាដួលស្រុញលើដី ។

រតនា ឈរច្រត់ចង្កេះបោះសំដីរ៉ាវដូចទឹកជ្រោះអូយ៉ាដាវ :

-មើល ! អាណាចង់សាកជាមួយនារីភ្នំពេញទៀត ! អញនឹងជួយបញ្ជូនទៅកាន់ឋានភុជង្គនាគឯបាតសមុទ្រកែបអោយហើយទៅ!

អានាក់លេងទាំងពីរដឹងខ្លួនថាខកដំណើរហើយ ព្រោះវាមើលច្រឡំ ក៏នាំគ្នាប្រឹងរត់យកប្រាសអាយុរៀងខ្លួន ។

ទេសចរដទៃទៀត ស្ងើចសរសើររតនាក្រៃលែង គេមិនស្មានថានារីទន់ល្វតល្វន់ដូចរតនាអាចធ្វើអោយអ្នកលេងជើងឆើតពីរនាក់រត់លែងងាកក្រោយក្នុងរយៈពេលដ៏ខ្លីយ៉ាងនេះសោះ ។

ពេលនោះ បូផល បានរត់មកដល់ដែរ :

-មានរឿងអ្វីឬ អូន ?



-ចាំស គ្មានរឿងអីទេ ! មានអាចំកួតពីរនាក់ណាទេល្ងីល្ងើមក អោយអូនជួយធ្វើសរសៃអោយវា ឥឡូវអូនបានបញ្ជូនវាអោយរត់លែងងាកក្រោយទៅហើយ មកបងយើងទៅងូតទឹកលេងខាងណោះវិញ ។ នៅទីនេះគេ មើលងាយយើងច្រើនណាស់ !

-អស្ចារ្យ ! រតនា ! ស្រលាញ់អូនជិតមួយឆ្នាំហើយ បងឥតដឹងថាអូនមានសមត្ថភាពដល់ម្លឹងសោះ !

កុំបញ្ឆោរអូនពេក ! នេះគ្រាន់តែជាកីឡាកាយសម្ព័ន្ធសំរាប់ជួយអោយសុខភាពល្អតែប៉ុណ្ណោះ ! បងកុំសូវចាប់អារម្មណ៍ពេក ! មកបង !

បូផល ដឹកដៃសង្សារ ហើយនាំគ្នាផ្លាស់សំលៀកបំពាក់ចុះមុជទឹកយ៉ាងសប្បាយ ។

គេមុជហែលដេញប្រឡែងគ្នាយ៉ាងសប្បាយ ដោយឥតគិតពីការលំបាក ឬទុកអ្វីឡើយ នេះពិតជាស្នេហ៍ក្នុងយុវវ័យមែន ។

ពេលដែលគេទាំងពីរកំពុងសើចក្អាកក្អាយក្នុងទឹក បុរសម្នាក់មានឯកសណ្ឋានជាប៉ូលីសដើរមកឈរចាំនៅមាត់ច្រាំង ។

បូផល មុជទឹករត់គេចពីការដេញចាប់របស់សង្សារបន្តិចរួចងើបមកវិញ នាយឃើញបុរសនេះក៏ប្រាប់សង្សារ :

-រតនា ! មានគេមករកបង !

ថាតែប៉ុណ្ណោះ បូផលប្រញាប់ហែលឡើងគោក បុរសនោះគំនាប់ផ្ទង :

-លោកអធិការមានទូរលេខផ្ញើមកលោក !

-មកដល់ពីស្មើណា !

-អម្បាញ់មិញ !

ជននោះហុចទូរលេខមកបូផល នាយទទួលយកមកអាន ឃើញមានសេចក្ដីថា :

-លោកអធិការបូផល សូមវិលមកកាន់រដ្ឋធានីជាប្រញាប់។ ថៅកែឈុនកំពុងត្រូវគំរាមកំហែងដល់ជីវិតនេះជាពត៌មានសំងាត់។

ស្នងការដ្ឋាន!

បូផលហុចក្រដាសទូរលេខទៅភ្នាក់ងារអម្បាញ់មិញវិញ :

-អស់ការ ! លោកដុតចោលចុះ !

-បាទ !

ភ្នាក់ងារពិសេសចុចដែកកេះហ្គាសហើយដុតទូរលេខសំងាត់ចោល ។



-អស់ការ ! ខ្ញុំលាសិនហើយលោកអធិការ !

-សូមអញ្ជើញ !

ភ្នាក់ងារសំងាត់ចេញផុតទៅ រតនាឡើងមកដល់

-មានការអីហ្នឹងបង ?

-គ្មានអីទេ ! តែថៅកែឈុនមានការគំរាមកំហែងដល់ជីវិត!

-អ្នកណាជាអ្នកប្រព្រឹត្តអំពើនេះ ?

-ក្អែបខ្មៅ !

-បងទៅឥឡូវឬ ?

-ត្រូវហើយ ! បើបងមិនទៅទេ គ្មានអ្នកណាហ៊ានទប់ទល់ជាមួយក្អែបខ្មៅទេ !

-បងស្មានថា ក្អែបខ្មៅអោយបងជួបមុខឬ ?

-វាមិនអោយទេ ! តែគង់បានជួបគ្នាមិនខាន ! មកអូនយើងត្រឡប់ទៅវិញ !

-ទេ ! អូនឥតចង់ទៅទេ ! មកលេងមិនទាន់បានអី ត្រឡប់ទៅវិញហើយ ....

-កុំងរពេកអូន ! ចាំថ្ងៃក្រោយបងជូនអូនមកទៀតណា !

ទោះចង់មិនចង់ រតនាត្រូវតែរៀបចំខ្លួនត្រឡប់ទៅវិញតាម

សង្ស័យដែរ ។

រថយន្តបានវិលមកដល់ភ្នំពេញវិញនៅរសៀលថ្ងៃដដែរ ។

គ្រាន់តែជូនសង្ស័យទៅដល់គេហដ្ឋានភ្លាម បូផលប្រញាប់ទៅកាន់ស្នងការដ្ឋានជាបន្ទាន់ :

សូមគោរពលោកស្នងការ ! តើមានហេតុភេទអ្វីគួរចាប់អារម្មណ៍ទេ ?

លោកស្នងការជក់បារីស៊ីហ្គាបង្ហុយផ្សែងទៅលើ :

-ក្រោយពីទទួលសញ្ញាក្អែបខ្មៅដោយសំងាត់មក លោកចៅកែឈុនមិនទាន់បានទទួលហេតុផលអ្វីគួរកត់សំគាល់ទេ ! តែបើតាមខ្ញុំស្មានព្រឹត្តិការណ៍នេះប្រហែលជាឆ្ងងមិនផុតពីយប់នេះទេ !

-ខ្ញុំឆ្ងល់ណាស់ ! ក្រោយពីទទួលការគំរាមកំហែងពីសំណាក់ក្អែបខ្មៅហើយ ហេតុដូចម្តេចក៏ចៅកែឈុនគ្មានមធ្យោបាយទប់ទប់ដើម្បីសេចក្តីសុខរបស់ខ្លួន !

-មិនអត់ទេ ! លោកដឹងទេ គ្រាន់តែក្អែបខ្មៅប្លន់ប្រាក់មួយលានរៀលរបស់លោកឈុន គាត់បានជួលពួកអ្នកលេងយ៉ាងច្រើនការពារវិទ្យារបស់ គាត់ និងតាមការពារគាត់ជាប់ជានិច្ច បើសិនជាក្អែបខ្មៅលេចមុខនៅពេលនេះខ្ញុំជឿថា ប្រហែលជាគេចមិនផុតពីដៃជើងរបស់គាត់ទេ!



បូផល ជ្រួញចិញ្ចើម :

-បើដឹងថាអាចទប់ទល់បានហើយ ចាំបាច់លោកស្នងការតាមខ្ញុំមកធ្វើអី ?

-មិនមែនតាមលោកអោយមកការពារលោកឈុនទេ គឺយើងត្រូវការចាប់ក្របួចក្អែបខ្មៅដែរណា ! លោកភ្លេចហើយកាលក្អែបខ្មៅយកសញ្ញារបស់វាមកគំរាមលោកឈុននៅមុខការិយាល័យរឿងនេះ ចាត់ទុកជាការប្រមាថមើលងាយដល់ក្រុមសំងាត់សំបើមណាស់ណា!

ចាត់ទុកថា ជាការមើលងាយទៅចុះ តែអំពើរបស់លោកឈុន ក៏បានធ្វើអោយក្រុមសំងាត់យើងវង្វេងដែរណា !

រឿងនេះត្រូវទុកមួយឡែកសិន ! ចំពោះមុខនេះ យើងត្រូវតែក្រសោបញិចក្អែបខ្មៅសិន បញ្ហាអំពើរបស់ចៅកែឈុន យើងនឹងរកវិធានការតាមក្រោយ ព្រោះវាជាការងារស្រួលជាងវត្ថុមានរបស់ក្អែបខ្មៅ ។

-តើលោកមានបញ្ជូនគ្នាយើងអោយទៅឃោមឃ្លាំមើលវិមានរបស់លោកឈុនទេ ?

-មាន ! សែម និងគ្នាយើងមួយចំនួនបង្កប់ខ្លួនជុំវិញវិមានដោយថៅកែឈុនឥតដឹងឡើយ ។

-បើដូច្នេះ ខ្ញុំសូមលាលោកសិនហើយ !

បូផល គោរពលាលោកស្នងការ ហើយចាកចេញពីស្នងការដ្ឋានជាបន្ទាន់ ហើយបង្កប់ខ្លួនយ៉ាងរហ័សទៅក្នុងចំណោមជនានុជនដ៏ច្រើនកុះករនៃរដ្ឋធានី ។

យប់ស្ងាត់ ស្បៃខ្មៅងងឹតនៃរាត្រីកាលបានទំលាក់វាំងននគ្របដណ្ដប់លើរដ្ឋធានីភ្នំពេញទាំងមូល ។ យូរៗយើងឃើញរថយន្តធំបើកកាត់តាមវិថីដោយបញ្ចេញស្នូរសន្ធឹកដូចរន្ទះ ។

វិមានរបស់លោកឈុន មានពន្លឺបំភ្លឺព្រោងព្រាតហើយគេអាចឃើញមនុស្សដើរចុះដើរឡើងមិនស្ងវដាច់ ហាក់ដូចជាមានការចាំបាច់ណាស់ក្នុងវិទ្យានេះ ។

សត្វចង្រិតយំបញ្ចេញសំលេងច្រេចៗ ពីគុម្ពស្មៅប្រគួតនឹងសំលេងចំរៀងដែលលាន់រងំពីវិទ្យុស្រូបសំលេងដែលគេបានបើកឯក្នុងអាគារនៃគេហដ្ឋាន ។

នៅក្នុងបន្ទប់ទទួលភ្ញៀវ ថៅកែឈុនអង្គុយបន្តិចឈរបន្តិចរួចក្រោកដើរក្រពាត់ដៃទៅក្រោយដោយច្រាសច្រាលក្នុងចិត្ត ។



អ្នកស្រីជាភរិយាអង្គុយធ្វើមុខស្រពោនលើកៅអីពូកដោយឥតចេញស្ដីមួយម៉ាត់ ។

-ម៉ឹង ១ ! ១ !

នាឡិកាប៉ោលចាប់ផ្ដើមគោះរគាំងបន្លឺសញ្ញានៃពេលវេលា។

-ម៉ោងដប់ទៅហើយ ! ក្អែបខ្មៅមិនទាន់ឃើញមកតាមការណាត់ទេ ! អូនយល់ថាក្អែបខ្មៅវាមិនហ៊ានមកទេ !

សំដីរបស់ភរិយាថៅកែឈុន ធ្វើអោយលោកឈុនមានកំហឹងគួរសម គាត់មើលមុខប្រពន្ធ :

-ឯងចង់អោយវាមកណាស់ទៅឬ ?

-ទេ ! អូនមិនចង់អោយវាមកទេ តែអូនសន្និដ្ឋានថាវាមិនហ៊ានមកណាបង !

-កុំអាលសន្និដ្ឋានងាយពេក ! បើយើងប្រាប់អោយគ្នីគ្នាការពារអោយបានហ្មត់ចត់នោះទើបវាប្រសើរជាង !

-យើងការពារមាំទាំយ៉ាងនេះហើយ តើក្អែបខ្មៅវាហ៊ានមកទៀតទេ ?

-ហ៊ាន ឬ មិនហ៊ានយើងមិនអាចសន្និដ្ឋានបានទេ តែគួរអូនឯង

ពិចារណាពីករណីលោកវេជ្ជបណ្ឌិតសំអាតដែរណា ! គិញសំងាត់នៅច្រូងដូចរបងទៅហើយនៅភ្ញាត់អោយវាចូលបាន !

-កាលណោះវាបានលេសយកអ្នករបួសចូល ឯយើងគ្មានករណីនេះទេណា !

-គ្មានករណីនេះមែន តែអាចមានករណីពិសេសផ្សេងទៀតណា!

-ដូចជាមិនទំនងសោះ !... បងបារម្ភណាស់ទៅ !

-ត្រូវហើយបងបារម្ភ !

-អូនឆ្ងល់ណាស់បង ! ហេតុដូចម្ដេចបានជាថៅកែគគោកនៅ ភ្នំពេញដែលមានជាងយើងទៀត វាមិនប្លន់ ។ ឆ្ងាញ់អីតែយើង ...ឬក៏បងមានទាក់ទងអីជាមួយនឹងវា !

សំណួររបស់ភរិយាធ្វើអោយលោកឈុនហាក់ដូចជាមានការតប់ប្រមល់ក្រៃលែង គាត់ពោលបន្ទរ :

-ទាក់ទង ! ទាក់ទងអី ! បើមានការទាក់ទងជាមួយវាហេតុអីក៏ វាមកប្លន់បង ?

-អូនមិនដឹងទេ ! តែអូនបារម្ភពេកចេះតែគិតទៅណា !

-យប់ណាស់ហើយ ! អូនឯងទៅគេងទៅ ! ទុកអោយបង



នៅតែម្នាក់ឯងបានហើយ !

-អូនបារម្ភចំពោះបងណាស់

-បារម្ភចេះតែបារម្ភហើយ ! តែការដែលយើងពង្រាយគ្នាញឹកយ៉ាងនេះ តើវាអាចជ្រៀតចូលមករួចទេ ! បងថាច្បាស់ជាមិនរួចទេ ! ទៅគេងមុនទៅអូន !

អ្នកស្រីឥតនិយាយក្រោកដើរទៅកាន់បន្ទប់សំរាក ដោយទុកអោយលោកឈុននៅក្នុងបន្ទប់ទទួលភ្ញៀវតែម្នាក់ឯង ។

នាឡិកាប៉ោលវាយម៉ោងដប់មួយទៀត ថៅកែឈុនចាប់ផ្ដើមស្វាបហ៊មៗ ! ដោយភាពងុយងោក ។ គាត់ដើរទៅដាក់គន្លឹះបិទទ្វារ ហើយបិទបង្អួចម្ដងមួយៗ ។ នៅសល់បង្អួចមួយទៀតដែលត្រូវបិទបង្អួយ .... ស្រាប់តែ .....

-ក្អក !

សំលេងធ្លាក់មួយលាន់ឡើង ថៅកែឈុន ព្រឺសំបុរគីង្គក់ហើយងាកយ៉ាងរហ័ស ....

សក់គាត់ស្ទើរតែបះឈរត្រង់ឡើងលើ ព្រោះនៅពីមុខគាត់រូបក្អែបខ្មៅមួយគ្របស្រប៉ាបលើកំរាលការ៉ូ ....

ថៅកែឈុនស្ទុះទៅរើសរូបក្អែបនោះ ទន្ទឹមគ្នានោះស្នូរព្រឹប

ខាងក្រោយខ្នងគាត់ ... ថៅកែឈុនត្រជាក់ឆ្អឹងខ្នងចង់ខ្យល់គរ ងាកក្រោយផាំង ... គាត់ស្ទើរលេចនោមបន្តិចលេចអាចម៍បន្តិច ព្រោះមនុស្សខ្មៅម្នាក់ឈរមុខបង្អួច ... ពិតជាក្អែបខ្មៅទាំងសាច់ទាំងឈាមតែម្តង ។

ក្រសែភ្នែកព្រិចៗ សំលឹងចេញពីសំពត់បិទមុខខ្មៅ បង្ហាញភាពក្លាហានមុះមុត ។

ថៅកែឈុនស្ទើរហាមាត់ចង់ស្រែក តែ ... ក្អែបខ្មៅបង្ហាញកាំភ្លើងខ្លីហើយដើរមកមុខគាត់ៗ ថយក្រាកៗ ! រហូតដល់ផ្ទាច់នឹងជញ្ជាំង !

-ថៅកែឈុន ! ឯងស្មានថាយើងមិនហ៊ានមកឬ ?

ហ៊ឹស ! យល់ច្រឡំហើយ តែយើងថាមកយើងត្រូវតែមក ទោះជាមានជញ្ជាំងលង្ហិន ឬ កំផែងលំពែងរាប់សិបជាន់ក៏ដោយ...

ថៅកែឈុនរេភ្នែករកទ្វារ តែ ...

-ឥតប្រយោជន៍ទេថៅកែឈុន ! បើអ្នកឯងហ៊ានកំរើកតែបន្តិចនោះយើងនឹងសំលាប់ឯងចោលភ្លាម ... ឯងស្មានថាយើងគ្មានសមត្ថភាពឬ ? ហ៊ឹស ! យល់ច្រឡំហើយកាំភ្លើងរបស់យើងមានប្រដាប់ខ្ចប់សំលេងមិនអោយឮសូរបាន ដូច្នេះយើងអាចបាញ់



អ្នកឯងមិនអោយឮសូរទៅក្រៅបានទេ !

ថៅកែឈុនលេបទឹកមាត់ក្អឹកៗ ដើម្បីផ្សើមបំពង់ក :

-អ្នកឯង ! អ្នកឯង ! តាមចងពៀរយើងដល់ណាទៀត

-ចងពៀរ ! ហាស់ៗ ! ៗ ! យើងមិនចងពៀរនឹងឯងទេ ! ថៅកែឈុន ! ឯងមាននឹកឃើញនូវអំពើរដែលឯងបានប្រព្រឹត្តកន្លងមកទេ ?

-អំពើអីទៅ ! យើងជាអ្នករកស៊ី ! គ្មានអំពើអ្វីក្រៅពីជំនួញរបស់យើងទេ !

-គ្មាន ! ពិរោះណាស់ថៅកែឈុន ! ឯងមានរំលឹករឿងពីអតីត-កាលទេ ? ការជួបយើងលើកមុន យើងបានបញ្ជាក់ហើយថាអោយឯងឆាប់សារភាពរឿងពីអតីតកាលដែលឯងបានប្រព្រឹត្តិ តែឯងមិនព្រមភ្ញាក់ខ្លួនសោះ ឯងខំរកដៃជើងដើម្បីកំចាត់យើងដែលជាអ្នកការពារអំពើយុត្តិធម៌ ។ ឯងធ្វើនេះក្នុងគោលបំណងបិទបាំងអំពើទុច្ចរិតស្មោគគ្រោករបស់ឯងមែនទេ ?

-ទេ ! យើងឥតបានប្រព្រឹត្តអំពើស្មោគគ្រោកនេះទេ កុំមកចោទយើង ! អ្នកឯងចង់បានអី ? តាមពិតគឺ ..... ឯងទេ !

-ឈប់មាត់ថៅកែឈុន ! ហើយឯងកុំចង់និយាយខ្លាំងៗ ដើម្បី

អោយសញ្ញាទៅដៃជើងឯងខាងក្រៅអោយសោះឥតអំពើទេ ព្រោះយើងមានឧបករណ៍តិចនិចដើម្បីស្រូបសំលេងនេះយកអស់ ហើយ ! យើងសូមសួរឯងថា តើឯងមានទឹកឃើញរឿងសោកនាដកម្មនៅតាមដងផ្លូវជាតិលេខប្រាំមួយក្បែរជើងភ្នំសន្ទុកទេ ?

-ភ្នំសន្ទុក !

-ត្រូវហើយ ! កាលពីដប់ប្រាំឆ្នាំមុន !

មុខរបស់ថៅកែឈុនស្រាប់តែប្រែជាស្លេកស្លាំងភ្លាមមួយរំពេច ។ ដៃជើងគាត់ញ័រទទ្រើត ជាមួយនឹងសំលេងខ្សាវៗ :

-ឯង ! ឯង ! ... ឯងជានរណា ?

-យើងជានរណាឬ ? ហាស់ៗៗ ឯងកុំចង់ស្គាល់អី ឯងគ្រាន់តែដឹងថាយើងនេះជាសាក្សីម្នាក់ដែលបានឃើញអំពើឯងផ្ទាល់ភ្នែកដោយគ្មានលទ្ធភាពនឹងតស៊ូជាមួយឯង ហើយនឹងមិនទាន់យល់ថាអំពើរបស់ឯងជាអ្វីនៅឡើយផង ... ហ៊ឹស ... ឯងមិនបាច់ចង់ស្គាល់យើងនាំអោយភ័យព្រួយទេ សំខាន់បំផុតគឺឯងត្រូវតែជំរះបញ្ជីនេះអោយជ្រះស្រឡះក្នុងថ្ងៃនេះ ...

-បញ្ជី ? តើបញ្ជីឯងអីទៅ ! យើងឥតបានយករបស់គេទេ..

-ឯងមិនបានយកនៅពេលនេះមែន តែក្រោយមកឯងបែក



គ្នាមែនទេ ?

ថៅកែឈុនកាន់តែភ័យស្ទន់ស្ទោមែនទែន ហើយក្នុងក្រសែភ្នែករបស់គាត់ហាក់ដូចជាមានសញ្ញានៃវិប្បដិសារីមួយរកពោលមិនបាន គាត់កំពុងតែលង់ក្នុងសមុទ្រនៃមនោសញ្ចេតនាមួយទាល់ច្រកមែនទែន ។

-យើង ! យើង ! ... រកទឹកមិនឃើញថា .... យើងបានប្រព្រឹត្តអំពើដែលឯងចោតសោះ .....

-ថៅកែឈុន ! ការដោះសាររបស់ឯងជាការឥតអំពើទេ ! ឯងនេះកាលដើមមិនមែនឈ្មោះឈុនទេ គឺឯងឈ្មោះ *ផោម*ជាពាណិជ្ជករតូចតាចនៅភ្នំពេញប៉ុណ្ណោះ ... តែក្រោយដែលឯងបានចូលរួមជុំគំនិតនឹងអាថៅកែសំរ៉ាំង និងដុកទ័រសំអាត និងពីរបីនាក់ទៀតដែលយើងរកមិនទាន់ឃើញមក ឯងស្រាប់តែក្លាយទៅជាអ្នកមានយ៉ាងធំតែម្តងមែនទេ...

-ថៅកែឈុនត្រូវអស់អែកដោយពុំដឹងរកច្រកណាឡើយភេរវជនបន្តប្រយោគ :

-លឿនឡើង ! ឆាប់សំរេចចិត្តទៅ ឯងអោយយើងជំរះបញ្ជីដោយប្រើចុងកាណុងយើង ឬក៏ឯងព្រមសងបំណុលដោយខ្លួន

ឯង?

-បំណុលអីទៅ ?

ថៅកែឈុនសួរដោយបើកភ្នែកធំៗ តាមពិតគាត់យល់ណាស់ទៅហើយ តែចំពោះមុខមច្ចុរាជសំរាប់ជីវិតគាត់ គាត់ត្រូវតែធ្វើពើដូចភ្លើបន្តិចដូចភ្លួតបន្តិច ។

ភេរវជនបន្ត :

-យើងបញ្ជាក់អោយហើយ ! កូនប្រុសរបស់ឯងដែលកំពុងរៀននៅបរទេស និង ប្រពន្ធរបស់ឯងក៏យើងមិនទុកដែរ បើឯងមិនព្រមសងបំណុលនេះដោយខ្លួនឯង តែបើឯងព្រមសងដោយខ្លួនឯងនោះ យើងនឹងអនុគ្រោះទុកជីវិតអោយអ្នកទាំងនោះយ៉ាងម៉េចសំរេចចិត្តទៅ !

ថៅកែឈុនមានមុខស្លេកដូចសោះឈាមទៅហើយ គាត់នឹកស្តាយចំពោះអំពើដែលបានប្រព្រឹត្តកន្លងមកក្រៃលែង ។ ពេលនេះទើប គាត់ដឹងថាអំពើដ៏លាមករបស់គាត់បានហុចផលអាក្រក់ដល់គាត់ហើយ ពិតជាឈាមស្រែកស្បែកហៅមែន ។ តែទំរាំពេលគាត់ដឹងខ្លួននៅពេលនេះ ហួសពេលទៅហើយអ្វីៗសុទ្ធតែហួសអស់ដោយគ្មានពេលវិលត្រលប់ឡើយ ។



ក្នុងដង្ហើមចុងក្រោយ ថៅកែឈុនដែលធ្លាប់តែរឹងប៉ឹងក្លាហាន បែរជាត្រូវកំសាក ហើយលុតជង្គង់ចុះ :

-សូម ... សូមលោកកុំធ្វើបាបខ្ញុំ ... អ្វីៗកន្លងហួស មកពីខ្ញុំធ្វើតាមគេទេ ! បើអ្នកឯងយកអ្វីពីយើងក៏យើងអោយដែរ ...

-បាន ! យើងព្រមយកជីវិតអ្នកឯងតែម្នាក់គត់ សូមឯងប្រគល់មកចុះ !

ពាក្យដើមដំបូងថៅកែព្រេកអរដូចកើតម្តងទៀត តែពាក្យមួយប្រយោគក្រោយធ្វើអោយគាត់អស់សង្ឃឹមរលីងគេង ហើយតំនក់ទឹកភ្នែកចាប់ផ្តើមស្រក់ចុះ ។

ក្អែបខ្មៅបន្ត :

-យើងបានយកផ្លាកក្អែបខ្មៅមកពាក់ដើម្បីអោយឯងដឹងខ្លួន តែឯងមិនព្រមដឹងខ្លួនសោះ ! ហ៊ឹស... ឥលូវសំរេចភ្លាមទៅ... អោយយើងអនុគ្រោះប្រពន្ធកូនឯងទេ ?

ថៅកែឈុនលើកដៃសំពះ :

-បាទ ! សូមលោកទុកតែជីវិតប្រពន្ធកូនខ្ញុំចុះ ...

-ហ៊ឹសៗ " ជនអាថ៌កំបាំងសើចក្នុងដើមក " កាលពីដប់ប្រាំឆ្នាំមុន បើលោកទទួលពាក្យអង្វរនឹងម្រាមដៃសំពះរបស់នារីម្នាក់នោះ

ឧក្រិដ្ឋកម្មប្រហែលជាមិនអាចកើតឡើងទេ មែនទេ ! ឯងសំពះសុំអោយគេអនុគ្រោះដែរ តែឯងមិនព្រមអនុគ្រោះអោយគេផងសោះ។ តែមិនអីទេ ! យើងអនុគ្រោះតាមសំណូមពររបស់ឯងហើយ ... ទៅលឿនឡើង ធ្វើអត្តឃាតភ្លាមទៅ យើងគ្មានពេលចាំយូរទេ ! យើងសន្យាជាឧឡារិកថា យើងនឹងមិនតាមព្យាបាទប្រពន្ធ និង កូនរបស់ឯងទេ !

ថៅកែឈុនតក់ស្លុតមែនទែន គាត់ចាប់ភ្លឹកដល់ការធ្វេសប្រហែសរបស់ក្អែបខ្មៅ ក៏ស្ទុះហៃទៅប្រុងកញ្ឆក់កាំភ្លើង តែ ...

ក្អែបខ្មៅរហ័សជាងគាត់ទៅទៀត គេវេខ្លួនបន្តិចយ៉ាងប៉ិនប្រសព្វ ហើយលោតទាត់ផាច់ ! ...

លោកឈុន ត្រូវមួយជើងចំចង្កា បណ្តាលអោយគាត់វិលមួយជុំ ហើយដួលលើកំរាល :

-ស្តាប់អោយច្បាស់លោកឈុន ! ផ្លូវរើអោយរួចខ្លួនគ្មានទេ ! មុនយើងមានលទ្ធភាពដូចថ្ងៃនេះ យើងបានសំងំហាត់រៀនក្បាច់ប្រយុទ្ធអស់រយៈពេលជិតដប់ឆ្នាំឆ្លងកាត់ទីក្រុងធំៗ ដូចជាតូក្យូ តៃប៉ិនិងសេអ៊ូល ! យើងមិនអោយឯងហក់រួចបានផុតពីជើងទីបីរបស់យើងទេ! ណ្ហើយចុះបើឯងមិនស្រលាញ់ប្រពន្ធកូនទេ យើងក៏មិន



បង្ខំឯងដែរ តែសូមឯងពិចារណាអោយបានស្រួលទៅកុំស្តាយក្រោយ ច្រកចេញមានតែមួយ គឺផ្លូវយកជីវិតមកសងជីវិតតែប៉ុណ្ណោះ ។

ក្អែបខ្មៅឈរជ្រែងចង្កេះយ៉ាងសង្ហា ហាក់ដូចជាយមរាជចាំឈរទារយកព្រលឹងរបស់ថៅកែឈុន ។

អស់ផ្លូវកែហើយ ថៅកែឈុនតក់ស្លុតហួសវិស័យនឹងពតឹនាបាន ។ គាត់ងើបមុខឡើងសស្លេកគ្មានឈាម សំលឹងមុខដែលពាសក្រណាត់ខ្មៅរបស់យមរាជ ហើយវេភ្នែកសំលឹងមើលពិភពលោកជាចុងក្រោយ :

-ណ្ហើយ ! យើងសុខចិត្តធ្វើអត្តឃាតដើម្បីលុបលាងកំហុសរបស់យើងកាលពីដប់ប្រាំឆ្នាំមុន នៅជើងភ្នំសន្ទុកចុះ តែឯងត្រូវតែគោរពពាក្យសន្យាដែលថាឯងមិនរករឿងកូនយើង និងប្រពន្ធយើងទេណា!

-យើងគោរពសំដីយើងជានិច្ច !

ថៅកែឈុនអង្គុយផ្អែកនឹងកៅអីសាឡុង គាត់ទាញយកកាំបិតស្នៀតដែលជនអាថ៌កំបាំងបានដាក់លើតុ ហើយសំលឹងវាជាចុងក្រោយ ...

ភ្នែករបស់គាត់ហាក់បង្កប់នូវភាពសោកស្តាយក្រៃលែង ។ ពេលនោះគាត់ធ្មេចភ្នែកហើយលើកកាំបិតឡើងដោយដៃញ័រទទ្រើត

ពីមុខគាត់ ក្អែបខ្មៅ ឈរសំលឹងឥតព្រិច ចុងកាំភ្លើងរបស់គេភ្ជង់ទៅមុខជានិច្ច ...

ថៅកែឈុនខាំមាត់ ញើសស្រក់តក់ៗ កាត់ចិត្តដាច់អហង្ការ ហើយបុកកាំបិតជ្រូក ...

ឈាមបាញ់ភុលតាមមុខកាំបិត ដែលដោតលើទ្រូងគាត់ ហើយហូរល្អាចល្អឹមលើកំរាល ... ភ្លាមនោះ ...

-ផស់ៗ ...

ក្អែបខ្មៅសង្កត់កៃបញ្ជាគ្រាប់ព្រួសចេញពីកាំភ្លើង ទៅទំលុះរាងកាយថៅកែឈុន បណ្តាលអោយតួសពាង្គកាយរបស់គាត់ស្រុតសន្សឹមៗ ហើយដួលស្រ៊ុបលើកំរាលឥដ្ឋ ។

ជនស្នៀកពាក់ខ្មៅស្រាប់តែសំរក់ទឹកភ្នែកតក់ៗ ហើយលុតជង្គង់ចុះលើកដៃសំពះបួងសួងទៅលើដោយពោលរអ៊ូៗ :

-លោកប៉ា ! អ្នកម៉ាក់ ! សូមវិញ្ញាណក្ខ័ន្ធរបស់លោកទាំងពីរបានស្ងប់ចិត្តនៅឯស្ថាននាយចុះ កូនបានសងសឹកជូនវិញ្ញាណក្ខ័ន្ធលោកទាំងពីរបានមួយហើយ នៅមួយចំនួនទៀត កូននឹងតាមទៅសំលាប់



វាសងឈាមជូនលោកទាំងពីរជាក្រោយទៀត .....

ក្អែបខ្មៅត្រូវផើបឈរយ៉ាងរហ័ស ព្រោះសំលេងមួយស្រែកហៅពីក្រៅ :

-បង ! បើកទ្វារ ! បងៗ ! ....

បន្ទាប់មកគឺស្នូរគោះទ្វារ .... ញាប់រន្ទើន ..... តុក តុកៗៗ

-បង ! បើកទ្វារ .... លឿនឡើង ! ....

ស្នូរជើងរត់ទីបៗ យ៉ាងរហ័ស .....

ក្អែបខ្មៅយល់សភាពការណ៍មិនស្រួល ប្រញាប់រត់ទៅកាន់បង្អួចមួយដែលចំហរ

ព្រមជាមួយនឹងសំលេងគាស់ទ្វារ និង ស្នូរសំលេងស្រែកកងរំពង .....

ក្អែបខ្មៅចាប់ខ្សែដែលពាក់លើបង្អួច គឺជាខ្សែដែលគេតោងឡើងអំបាញ់មិញ ហើយសំរូតទំលាក់ខ្លួនយ៉ាងរហ័សនៅក្នុងភាពងងឹតនៃរាត្រីកាល ។

## ស្រមោលក្អែបខ្មៅ

ការផ្ទើលឆោឡោបានកើតឡើងជាបន្ទាប់ ហើយស្នូរគាស់ទ្វារលាន់ក្តុងក្តាំង ទីបំផុតទ្វារក៏របើកឃ្វាំងឡើង ។ អ្នកស្រីជាភរិយាស្រែកយំដោយតក់ស្លុត :

-បង ! បងសំលាញ់ ! .... បងស្លាប់ហើយ .....

ថៅកែដេកត្រាំក្នុងថ្លុកឈាម ដោយមានកាំបិតមួយដោតចំកណ្តាលដើមទ្រូង ។

អ្នកស្រីឱបសពយំបោកខ្លួន លើកំរាលការ៉ូដោយអាណោចអាធម្មក្រៃលែង ។ អម្បាញ់មិញប្តីគាត់នៅនិយាយលេងជាមួយគាត់ប៉ប៉ោច ដល់មកឥឡូវប្តីគាត់មិនមែនជាមនុស្សដូចគាត់ទៀត



ទេ ។

នៅខាងក្រោមឯណោះ ក្អែបខ្មៅប្រតោងរបងផ្ទះចេញទៅក្រៅទៅហើយ តែត្រូវពួកឆ្កែបំរើថៅកែឈុនឃើញ :

-កនយើង ! ក្អែបខ្មៅនៅត្រង់ណោះ ... លឿន

ភ្លាមនោះការប្រដេញគ្នាក៏បានកិតណាស់ទៅហើយ រហូតដល់ក្អែបខ្មៅត្រូវធ្លាក់ក្នុងការហ៊ុំព័ទ្ធរបស់ពួកទាំងនោះ ។

គ្មានសំដីសំរាប់ឆ្លើយឆ្លងគ្នាទេ ការប្រយុទ្ធចាប់ផ្តើមបើកឆាកភ្លាម ។ ក្អែបខ្មៅមានថ្វីដៃប្រយុទ្ធឆើតក្រៃលែង យើងឃើញតែស្រមោលខ្មៅហើរវៀវៗ កណ្តាលរាត្រី ហក់ទាត់ពួកនោះយ៉ាងឆើត ។

-ចាច ! អាមួយហក់ពីចំងាយទាត់ក្អែបខ្មៅភឹង១ បង្ខំអោយភេរវជនលោតគេចយ៉ាងរហ័ស ហើយវាយសងវិញរឹប១... ធ្វើអោយវាគេចយ៉ាងទាន់ហន់ ។

អាម្នាក់ទៀតហក់មកដល់ជាបន្តបន្ទាប់លោតទាត់ក្បាលក្អែបខ្មៅបង្ខំអោយជនស្រមោលខ្មៅឱនគេចយ៉ាងស្វាហាប់ តែអាមួយទៀតក៏បានស្ទុះមកដល់ដែរ ... ក្អែបខ្មៅលោតគេចព្រមទាំងផាល់សងវិញយ៉ាងរហ័ស និងខ្លាំងក្លា ។

ឆាកប្រយុទ្ធមានភាពសាហាវគួរអោយស្ញើប ។

ពេលនោះ សំលេងស៊ីរ៉ែនជាសញ្ញា និងសំលេងរថយន្តលាន់ កងរំពង ... រថយន្តបើកឆ្វាត់ឆ្វៃលមកកាន់កន្លែងកើតហេតុ..

ក្អែបខ្មៅស្ទុះវាយបណ្តើរដកឃ្លាបណ្តើរ ដើម្បីរកច្រកគេចព្រោះគេមិនអាចបញ្ចប់ការប្រយុទ្ធដោយខ្លីបានឡើយ ។

គេបានស្ទុះមកដល់ច្រកងងឹត ហើយរត់យ៉ាងរហ័ស ....

ក្អែបខ្មៅរត់ហើយ ! ៗ ! ...

ក្អែបខ្មៅហក់តោងតាមសំយាបផ្ទះពីមួយទៅមួយយ៉ាងរហ័ស និងស្រាលស្តើកគួរសរសើរមិនខុសពីសត្វស្វាលោតទុំមែកឈើឡើយ ។

នៅខាងក្រោយឯណោះ ពួកឆ្កែបំរើនៅតែដេញតាមដដែល

រថយន្តមួយបើកយ៉ាងលឿនមកដល់ ....

ក្អែបខ្មៅលោតចូលក្នុងរថយន្តយ៉ាងរហ័ស ហើយក៏បើកចេញពីទីនោះភ្លាម .....

វាឡើងឡានចេញទៅហើយ .... វាឡើងឡានចេញទៅហើយ .....



រថយន្តបានកប់បាត់ក្នុងស្រមោលខ្មៅនៃរាត្រីកាល ធ្វើអោយពួកដេញតាមឆោឡោមួយរំពេច ។

ភ្លាមនោះ រថយន្តប៉ូលីសបានមកដល់ មនុស្សម្នាក់លោតចេញមក គឺបូផល :

_មានរឿងអី ឬ ?

_បាទ ! ក្អែបខ្មៅរត់ឡើងឡានមួយបើកចេញពីទីនេះទៅហើយ

_ឡានពណ៌អី ?

_ពណ៌ខ្មៅ .....

មិនបង្អង់យូរ អធិការបូផលរត់ឡើងឡាន ហើយបញ្ជាអោយបើកតាមឡានរបស់ក្អែបខ្មៅជាបន្ទាន់ ។

សំលេងរថយន្តប្រដេញគ្នាបានធ្វើអោយបរិយាកាសស្ងប់ស្ងៀមនៃទីក្រុង ក្លាយជាមានសភាពគគ្រឹកគគ្រេង ។

ស្រមោលរថយន្តខ្មៅនៅពីមុខលឹមៗ :

_ពិតជាឡានហ្នឹងហើយ ! តាមវាអោយកិតមែនទែន !

បូផលបញ្ជាអ្នកបើកយាន ។

រថយន្តបើកតាមផ្លូវធំបន្តិចក៏បត់តាមផ្លូវតូចកាច់ក្រវិចក្រវៀន ។

-បង្កំល្បឿនបន្តិចទៅ ! ..... បូផលបញ្ជា ។

រថយន្តបត់តាមផ្លូវផ្សារស៊ីឌិប ហើយបំបាំងនឹងកាច់ជ្រុងនៃគេហដ្ឋាន .....

-លោកបើកតាមវាពីក្រោយ កុំអោយដឹងខ្លួនអោយសោះណា!

-បាទ ! ចុះលោក ?

-ខ្ញុំទូរស័ព្ទហៅឡានមកយកឥឡូវ !

-បាទ !

រថយន្តប៉ូលីសបើចេញទៅភ្លាម ។ បូផលទាញយកទូរស័ព្ទហើយហៅរថយន្ត :

-អាឡូ ! មុខវិមានឯករាជ្យ ! សុំរថយន្តមួយមកទទួលជាបន្ទាន់!

បូផលទុកប្រអប់ទូរស័ព្ទ ហើយបើកនាឡិកាផ្ទៀងមើលម៉ោងមួយរំលងអាធ្រាតទៅហើយ ។ បរិយាកាសស្ងាត់ជ្រងុំក្រៅពីបង្គោលភ្លើងអគ្គិសនី សភាពខ្មៅងងឹតជាប់ពេញទីក្រុង ។

-ហ៊ឺ ! បូផលបន្ទូរដង្ហើម ដោយនឹកមិនអស់ចិត្តចំពោះភេរវកម្មរបស់ក្អែបខ្មៅសោះ :

-ហេតុដូម្ដេចបានជាក្អែបខ្មៅប្ដូររើសមុខឥចឹងតើពួកអស់ទាំងនេះមានទាក់ទងនឹងក្អែបខ្មៅពីដើមមកឬ ?



គួរអោយចំលែកណាស់ ! ពិសេសគឺនៅទីណាដែលនាយប្រុងនឹងទៅដល់ ! ក្អែខ្មៅហាក់ដូចជាដឹងខ្លួនមុន .... តើក្អែបខ្មៅជាមនុស្សដែលបង្កប់ក្នុងក្រុមប៉ូលីសជាមួយនាយដែរទេ ។

នាយត្រូវបញ្ឈប់ការត្រិះរិះគិត ព្រោះពេលនោះរថយន្តមួយបានមកដល់ហើយឈប់ពីមុខនាយ ។

-លោកអធិការ ហេតុអ្វីក៏មកខកដំណើរនៅទីនេះអីចឹង ?

-កុំអាលសួរ ! ជូនខ្ញុំទៅកាន់វិមានរបស់លោកថៅកែឈុនភ្លាម!

រថយន្តរោទិ៍ម៉ាស៊ី ហើយពុះជ្រែកស្បៃខ្មៅនៃរាត្រីកាលតំរង់ទៅកាន់កន្លែងកើតឃាតកម្ម ។

ចង្កៀងបំភ្លឺជុំទិស ញ៉ាំងអោយវិឡាមានសភាពដូចពេលថ្ងៃមនុស្សផ្អើលចោឡោមកមើលសភាពនៃឃាតកម្មដែលក្អែបខ្មៅបានបង្កើតឡើង ។

នៅកណ្ដាលបន្ទប់ទទួលភ្ញៀវ អ្នកស្រីជាភរិយាឥតព្រមដកឃ្លាចេញពីប្ដីឡើយ ទាល់តែភ្នាក់ងារប្រាប់ថា :

-សូមអ្នកស្រីបង្អន់ការយំស្រែកដើម្បីអោយគេពិនិត្យវត្ថុភស្តុតាង!

អ្នកស្រីក្រោកចេញទាំងទឹកមុខស្រពាក់ស្រពោន និងជោគ

ជាំដោយតំនក់ទឹកភ្នែក ។

គ្រូពេទ្យបានផ្ងារសពហើយពិនិត្យមើលកាំបិតស្នៀតដែលដោតឆ្កឹងលើដើមទ្រូង ។ បូផល ដើរទៅជិត :

-តើសាកសពស្លាប់ដោយកាំបិត ឬក៏ដោយគ្រាប់កាំភ្លើង លោកដុកទ័រ ?

លោកវេជ្ជបណ្ឌិតងើយមើលមុខបូផល :

-ស្នាមក្រៀមលើកាំបិតប្រព្រឹត្តទៅមុនគ្រាប់ដែលត្បុលចូលក្នុងទ្រូងសព ព្រោះកាំបិតស្នៀតចាក់ចូលមុន ទើបមានឈាមហូរច្រើនជាងស្នាមគ្រាប់ចូល ហេតុនេះហើយបានជាស្នាមគ្រាប់គ្មានឈាមសោះ !

អ្នកឯកទេសខាងពិនិត្យក្រយ៉ៅដៃបានអោយដឹងថា :

-លោកអធិការ ស្នាមក្រយ៉ៅដៃលើដងកាំបិតនេះ ជាស្នាមក្រយ៉ៅដៃរបស់សាកសពនេះកាន់ ! សាកសពប្រហែលជាធ្វើអត្តឃាតមុនឃាតករបាញ់សំលាប់ ...

បូផលងឿងឆ្ងល់ក្រៃលែង :

-ចំលែកណាស់ ! សញ្ញារបស់ក្អែបខ្មៅចូលមកអុកឡុកច្បាស់ក្រឡែត ហេតុដូចម្តេចបានជាលោកឈុនធ្វើអត្តឃាតកម្មទៅវិញ...



-នេះជាអាថ៌កំបាំងមួយបូកផ្សំនឹងអាថ៌កំបាំងមួយពីមុនមក " វេជ្ជបណ្ឌិត" វត្តមានរបស់ក្អែបខ្មៅគួរអោយព្រឺខ្លាចណាស់ ពិសេសសំរាប់ពួកអ្នកមានក្នុងក្រុងតែម្តង !

បូផលដើរក្រពាត់ដៃដោយតប់ប្រមល់ :

-ភេរវកម្មមួយហើយមួយទៀតឥតឈប់ឈរ តែស្រមោលរបស់ភេរវជននៅចាត់ឈឹងដដែល ! អស្ចារ្យណាស់ ខ្ញុំហាក់ដូចជាគ្មានសមត្ថភាពសោះក្នុងរឿងនេះ !

ការកត់ត្រា និងការថតរូបជាឯកសារបានចប់សព្វគ្រប់ព្រមជាមួយនឹងផ្ទៃមេឃចាប់ផ្តើមភ្លឺល្មម ។ លោកអធិការបូផលពោលទៅកាន់ភរិយាសព :

-លោកស្រី ! សូមរៀបចំទុកដាក់សពតាមគន្លងប្រពៃណីចុះណា ! អ្នកស្រីមានទឹកភ្នែករហាម :

-សូមលោកជួយរកឃាតករដើម្បីផ្តន្ទាទោសផង ! ...

-មិនអីទេលោកស្រី នេះជាភារកិច្ចរបស់ខ្ញុំហើយ ! តែការត្រួតពិនិត្យបានអោយដឹងថាប្តីអ្នកស្រីប្រហែលជាធ្វើអត្តឃាតមុនឃាតករបាញ់សំលាប់

-ពុទ្ធោ ! ទេ ! ខ្ញុំមិនជឿទេ គ្មានរឿងអ្វីដែលប្តីខ្ញុំត្រូវធ្វើអត្តឃាត